# ឯកសារទស្សនាទាន

# សិក្ខាសាលាពិគ្រោះយោបល់

# លើសេចក្តីព្រាងរបាយការណ៍វាយតម្លៃលទ្ធផលគម្រោង

# ស្តីពី "ការពង្រឹងសមត្ថភាពសង្គមស៊ីវិលដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងចីរភាពនៅកម្ពុជា (ដំណាក់កាលទី ៣)"

កាលបរិច្ឆេទ៖ ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២៦

ម៉ោង៖ ៩:00 ព្រឹក ដល់ម៉ោង ១២:00 ថ្ងៃត្រង់

ទីកន្លែង៖ (បញ្ជាក់ជូនពេលក្រោយ)

## I. សេចក្តីផ្តើម

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) ដោយមានការគាំទ្រផ្នែកហិរញ្ញវត្ថុពីសហភាពអឺរ៉ុប (EU) បាន និងកំពុងអនុវត្តគម្រោង «ការពង្រឹងសមត្ថភាពសង្គមស៊ីវិលដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងចីរភាពនៅកម្ពុជា (ដំណាក់កាលទី ៣)» ចាប់ពីខែមករា ឆ្នាំ២០២៤ ដល់ខែធ្នូ ឆ្នាំ២០២៦។ គម្រោងនេះមានគោលបំណងពង្រឹងសមត្ថភាពអង្គការសង្គមស៊ីវិល តាមរយៈការលើកកម្ពស់បរិយាកាសអំណោយផល និងលំហប្រជាធិបតេយ្យ ព្រមទាំងបង្កើនប្រសិទ្ធភាព ចីរភាព និងកិច្ចសហប្រតិបត្តិការជាមួយរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ។

អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) បានប្រគល់ការងារជូនទីប្រឹក្សាឯករាជ្យ ធ្វើការសិក្សាស្រាវជ្រាវលទ្ធផលនៃការអនុវត្តគម្រោង ការវាយតម្លៃលើភាពពាក់ព័ន្ធ ប្រសិទ្ធភាព ផលជះ និងចីរភាព ដើម្បីវាយតម្លៃបិទបញ្ចប់គម្រោងខាងលើនេះ។ ។ ការវាយតម្លៃនេះក៏កំណត់ផងដែរនូវសមិទ្ធផល បញ្ហាប្រឈម មេរៀនដែលទទួលបាន និងអនុសាសន៍នានា ដើម្បីជាមូលដ្ឋាន


www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009
#9-11, Street 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia
Accountability គណនេយ្យភាព
23/02/2023 GPP 22/02/2028
Symbol of Trust និមិត្តសញ្ញានៃនាមនុកមិត្ត

សម្រាប់រៀបចំកម្មវិធីនាពេលអនាគត និងពង្រឹងគណនេយ្យភាពចំពោះសហភាពអឺរ៉ុប ព្រមទាំងភាគីពាក់ព័ន្ធនៃគម្រោងផងដែរ។

មុននឹងបញ្ចប់របាយការណ៍វាយតម្លៃនេះជាស្ថាពរ អង្គការ គ.ស.ក នឹងរៀបចំសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងរបាយការណ៍វាយតម្លៃលទ្ធផលគម្រោង ដើម្បីបង្ហាញពីលទ្ធផលនៃការវាយតម្លៃ និងអនុសាសន៍នានាជូនដល់ភាគីពាក់ព័ន្ធ។ សិក្ខាសាលានេះនឹងផ្តល់ឱកាសក្នុងការធ្វៀងផ្ទាត់ភាពត្រឹមត្រូវនៃលទ្ធផលប្រមូលបាន ប្រមូលមតិយោបល់បន្ថែមពីភាគីពាក់ព័ន្ធ និងធានាថារបាយការណ៍ចុងក្រោយបានឆ្លុះបញ្ចាំងពីទស្សនៈចម្រុះ និងអនុសាសន៍ដែលអាចអនុវត្តបានជាក់ស្តែង។

## II. គោលបំណង

សិក្ខាសាលាសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងរបាយការណ៍វាយតម្លៃលទ្ធផលគម្រោងនេះ មានគោលបំណង៖

- បង្ហាញពីលទ្ធផល និងអនុសាសន៍នៃការវាយតម្លៃបញ្ចប់នៃគម្រោង។
- ពិនិត្យធ្វៀងផ្ទាត់ និងប្រមូលមតិយោបល់ ការបកស្រាយពន្យល់ ព្រមទាំងអនុសាសន៍នានាសម្រាប់ជាទិសដៅ និងគំនិតផ្តួចផ្តើមដើម្បីពង្រឹងសមត្ថភាពសង្គមស៊ីវិលនាពេលអនាគត។

## III. សមាសភាពចូលរួម

សិក្ខាសាលានេះ មានអ្នកចូលរួមប្រមាណ ៤០ នាក់ រួមមានតំណាងមកពី ប្រតិភូសហភាពអឺរ៉ុប បុគ្គលិកអង្គការ គ.ស.ក បណ្តាញអង្គការសង្គមស៊ីវិលថ្នាក់ខេត្តអង្គការសមាជិក អង្គការដៃគូអភិវឌ្ឍ អ្នកទទួលផលពីគម្រោង និងទីប្រឹក្សាឯករាជ្យវាយតម្លៃគម្រោង។

## IV. រៀបចាំ:

| ពេលវេលា | ប្រធានបទ | អ្នកសម្របសម្រួល |
|---|---|---|
| ០៨:៣០ – ០៩:០០ | ការចុះឈ្មោះអ្នកចូលរួម | ក្រុមការងារ គ.ស.ក |
| ០៩:00 – ០៩:១0 | មតិស្វាគមន៍ និងការបើកកម្មវិធី | លោក **ម៉ន្ត ភក្តី** |



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia

| | | |
|---|---|---|
| | | នាយកប្រតិបត្តិអង្គការ<br>គ.ស.ក |
| ០៩:១០ – ០៩:១៥ | ប្រកាសគោលបំណង និងរបៀបវារៈនៃសិក្ខាសាលា | អ្នកកាន់កម្មវិធី |
| ០៩:១៥ – ១០:១០ | ការបង្ហាញលទ្ធផលនៃការវាយតម្លៃបញ្ចប់គម្រោង៖<br>• លទ្ធផល បញ្ហាប្រឈម មេរៀនដែលទទួលបាន និងអនុសាសន៍<br>• សំណួរចម្លើយ | ទីប្រឹក្សាឯករាជ្ស |
| ១០:១០ – ១០:២៥ | សម្រាកអាហារសម្រន់ | អ្នកចូលរួមទាំងអស់គ្នា |
| ១០:២៥ – ១១:00 | ការពិភាក្សា និងមតិយោបល់ត្រឡប់<br>• ពិភាក្សាជាក្រុម ដើម្បីពិនិត្យផ្ទៀងផ្ទាត់ | ទីប្រឹក្សាឯករាជ្សនិងអ្នកចូលរួម |
| ១១:00 – ១១:៤៥ | ការធ្វើបទបង្ហាញលទ្ធផលពិភាក្សាតាមក្រុមនិងការពិភាក្សារួម | តំណាងក្រុមនីមួយៗ |
| ១១:៤៥ – ១២:00 | ការបូកសរុប និងបិទកម្មវិធី | លោក **ម៉ន្ត ភក្តី**<br>នាយកប្រតិបត្តិអង្គការ<br>គ.ស.ក |
| ១២:00 – ១៣:00 | សម្រាកអាហារថ្ងៃត្រង់រួមគ្នា | អ្នកចូលរួមទាំងអស់គ្នា |

***កំណត់សម្គាល់៖**

- អ្នករៀបចំកម្មវិធីសូមថតរូបវីដេអូ ឬសម្លេងសម្រាប់ការអប់រំផ្សព្វផ្សាយ និងកត់ត្រាកំណត់ហេតុ និង សូមរក្សាសិទ្ធិក្នុងការកែសម្រួលរបៀបវារៈខាងលើតាមការចាំបាច់។
- សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងអ្នករៀបចំកម្មវិធីលោក បេ ប៉ូរី តាមលេខទូរសព្ទ ០១៦ ៣៩៩ ៩២៥ ឬ borey.be@ccc-cambodia.org